# ទិវាកម្មសិទ្ធិបញ្ញាពិភពលោក

# "សិទ្ធិឯកាធិភាព និង សិទ្ធិផ្តាច់មុខ"

## ក្រសួងពាណិជ្ជកម្ម

២៨ មេសា ២០១៥

**វ៉ា រ័ត្នសាន**
ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម

# គោលបំណង

- នៅពេលបញ្ចប់បទបង្ហាញនេះ អ្នកចូលរួមនឹងអាចយល់ដឹង :
  - អំពីអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
  - យល់ច្បាស់អំពីផលប្រយោជន៍នៃការចុះបញ្ជីម៉ាក ដូចជា សិទ្ធិផ្តាច់មុខ
  - អំពីសិទ្ធិផ្តាច់មុខកម្មសិទ្ធិបញ្ញាទាក់ទងនឹងការនាំចូល និង សិទ្ធិឯកាធិភាព

# មាតិកា

I-ផលប្រយោជន៍នៃការចុះបញ្ជីម៉ាក

II-តើអ្វីទៅជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

III-សិទ្ធិផ្តាច់មុខកម្មសិទ្ធិបញ្ញានិងសិទ្ធិឯកាធិភាព

# I- ផលប្រយោជន៍នៃការចុះបញ្ជីម៉ាក

## A-រយៈពេលនៃការចុះបញ្ជីម៉ាក

## B- ផលប្រយោជន៍នៃការចុះបញ្ជីម៉ាក

# A- រយៈពេលនៃការចុះបញ្ជីម៉ាក (ប្រៀបធៀបជាមួយប្រទេសមួយចំនួន)

| ល.រ | ប្រទេស | រយៈពេល |
|---|---|---|
| 1. | កម្ពុជា | 6ទៅ 9 ខែ |
| 2. | អាស៊ាន | ៦ ទៅ ១២ ខែ |
| 3. | ជប៉ុន | ៨ ទៅ ១២ ខែ |
| 4. | សហរដ្ឋអាមេរិក | ១០ ទៅ ១៨ ខែ |

# B- ផលប្រយោជន៍នៃការចុះបញ្ជីម៉ាក

- ម្ចាស់ម៉ាកដែលបានចុះបញ្ជី បានសិទ្ធិផ្តាច់មុខទូទាំងប្រទេសកម្ពុជា ក្នុងការ:
  - ប្រើប្រាស់ជាម៉ាកដើម្បីកំណត់អត្តសញ្ញាណនិងផ្សព្វផ្សាយទំនិញ ឬសេវា ដែលបានចុះបញ្ជី

  (ប្រើប្រាស់ មានន័យថា នាំចូល នាំចេញ ផលិត  ដាក់លក់ លក់ មាត្រា ៦៦)
  - អនុញ្ញាតឬផ្តល់អាជ្ញាប័ណ្ណ ឱ្យអ្នកណាម្នាក់ ប្រើប្រាស់ម៉ាកក្រោមការត្រួតពិនិត្យរបស់ម្ចាស់ (មាត្រា ១៩)
  - កសាងតម្លៃបញ្ចូលក្នុងម៉ាកដែលបានចុះបញ្ជី

❖ ***ចាត់វិធានការច្បាប់*** ប្រឆាំងនឹងពាណិជ្ជករផ្សេងទៀត ដែលរំលោភបំពានម៉ាកដែលបានចុះបញ្ជី ក្នុងនោះ៖

- ❑ <u>ម៉ាកដែលដូចគ្នា</u>សម្រាប់ទំនិញ/សេវាដែលដូចឬប្រហាក់ប្រហែលដែលនាំឱ្យភាន់ច្រឡំ (មាត្រា ១១ខ)
- ❑ <u>ម៉ាកប្រហាក់ប្រហែល</u>ដែលនាំឱ្យភាន់ច្រឡំសម្រាប់ទំនិញ/សេវា ឬប្រហាក់ប្រហែលដែលនាំឱ្យភាន់ច្រឡំ (មាត្រា១១ខ)

❖ ប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច (គយ កាំកុងត្រូល ប៉ូលីសសេដ្ឋកិច្ច តុលាការ) ***ដើម្បីរារាំងការនាំចូល*** ទំនិញរំលោភបំពាន ឬទំនិញសង្ស័យរំលោភបំពាន ម៉ាក (មាត្រា ៣៥).


HI-TECH
evian
19 3 2005

# II. តើអ្វីទៅជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់(មាត្រា ២២និង២៣)

- ១) មាត្រា២២: អំពើនៃការប្រកួតប្រជែងណា ***ដែលផ្ទុយពីគោលការណ៍នៃការអនុវត្តទៀងត្រង់*** នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម ត្រូវចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់។
- នេះជានិយមន័យយ៉ាងទូលាយ និងរួមមានអំពើនានាដូចជា:
  - *ការបង្កូចកេរ្តិ៍ឈ្មោះគូប្រកួតប្រជែង*
  - *ការផ្សាយពាណិជ្ជកម្មដែលនាំឱ្យភាន់ច្រឡំ*
  - ការអូសទាញនិយោជិកសំខាន់ៗ ពីគូប្រកួតប្រជែង
  - ការលួចព័ត៌មានសម្ងាត់ផ្នែកពាណិជ្ជកម្ម។

## ➢ ២) មាត្រា ២៣ :

*ជាពិសេស* ទង្វើទាំងឡាយដូចខាងក្រោម ត្រូវចាត់ទុកថាបាន*បង្កើត*អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់៖

- ❖ *(a): ការបង្កើតឱ្យមានការ**ភាន់ច្រឡំ** តាមមធ្យោបាយណាមួយ* ជាមួយ<u>សហគ្រាស</u> ជាមួយ ***ទំនិញ*** *ឬជាមួយ**សកម្មភាព**ឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម **នៃគូប្រកួតប្រជែង**។*


LONGKOU
Vermicelli
龍口粉絲


LUNGKOW
Vermicelli
龍口粉絲


"CỌP ĐỎ"
CHICKEN INSTANT NOODLES
MÌ GÀ


CHICKEN INSTANT NOODLES
MÌ GÀ
鸡汁
VIFON
Khối lượng tịnh : 70g


Sprite


2L
SUNLY




Gleam

*(b):**ការពោលអះអាងមិនត្រឹមត្រូវ**ក្នុងពាណិជ្ជកម្ម ដែល**ធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ***

***សហគ្រាស ទំនិញ ឬ សកម្មភាព**ឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម **នៃគូប្រកួតប្រជែង**។*

***ឧទាហរណ៍:***

តើវាជាអំពើនៃការប្រកួតមិនស្មោះត្រង់ឬទេ?

មានបណ្ដឹងមួយពីក្រុមហ៊ុនBeeline ដោយអះអាងថា៖ វីដេអូខ្លីរបស់ក្រុមហ៊ុន Smart Mobile ជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

សូមមើលវីដេអូខ្លី ទាក់ទងនឹងការផ្សាយពាណិជ្ជកម្ម របស់ក្រុមហ៊ុន Smart Mobile រួចសូមវាយតម្លៃ។

❖ *(c):* **ការបញ្ជាក់ ឬការពោលអះអាង** ដែលបាន**ប្រើប្រាស់** នៅក្នុងពាណិជ្ជកម្ម ដែល**អាច**ធ្វើឱ្យសាធារណជន**ភាន់**ច្រឡំ អំពីប្រភេទ ការផលិត លក្ខណៈ ភាពសមស្រប សម្រាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ។

➢ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ដែលទាក់ទងយ៉ាងជិតស្និទ្ធនឹងម៉ាក គឺ *ការក្លែងបន្លំ* ។

*ឧទាហរណ៍:*
Pasterized (ទឹកដោះគោ)
មានវីតាមីន C (Dringking water)
ធម្មជាតិ100% (គ្រឿងសំអាង)
ស្តង់ដារអាមេរិក (រាល់ទំនិញទាំងអស់)
ផលិតក្រោមអាជ្ញាប័ណ្ណនៃ........ (រាល់ទំនិញទាំងអស់)

# III- សិទ្ធិផ្តាច់មុខ និងសិទ្ធិឯកាធិភាព

A- ការអនុវត្តជាអន្តរជាតិនៃការផុតរលត់សិទ្ធិ នៃកម្មសិទ្ធិបញ្ញា

A- ភាពផ្តាច់មុខនៃសិទ្ធិកម្មសិទ្ធិបញ្ញា

C- សិទ្ធិឯកាធិភាព

D- ដំណើរការ និងការដោះស្រាយវិវាទសិទ្ធិផ្តាច់មុខនៃការនាំចូល

# A- ការអនុវត្តជាអន្តរជាតិនៃការផុតរលត់សិទ្ធិកម្មសិទ្ធិបញ្ញា

1. ការផុតរលត់សិទ្ធិកម្មសិទ្ធិបញ្ញា (Exhaustion of IP Rights)
2. ការនាំចូលស្របគ្នា (Parallel Import)
3. ការផុតរលត់សិទ្ធិជាអន្តរជាតិ នៃសិទ្ធិលើម៉ាក (International Exhaustion of Mark Rights
4. គោលការណ៍ដែនដី នៃសិទ្ធិលើម៉ាក (Territorial Concept of Mark Rights)

# 1. ការផុតរលត់សិទ្ធិកម្មសិទ្ធិបញ្ញា (Exhaustion of IP Rights)

- ការផុតរលត់សិទ្ធិយោងដល់ការកម្រិត**សិទ្ធិ**កម្មសិទ្ធិបញ្ញា។
- នៅពេលដែលផលិតផលមួយដែលការពារដោយកម្មសិទ្ធិបញ្ញា ត្រូវបានលក់ដោយម្ចាស់សិទ្ធិ ឬ ដោយបុគ្គលដទៃ ដោយមានការយល់ព្រមពីម្ចាស់សិទ្ធិ ក្នុងការធ្វើអាជីវកម្មលើផលិតផលណាមួយនោះ លែងអាចអនុវត្តបានដោយម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញាហើយ ដោយសារផុតរលត់សិទ្ធិទាំងនេះ ។
- ជួនកាល ការកម្រិតនេះ ត្រូវបានហៅផងដែរថា៖ ***គោលការណ៍លក់លើកដំបូង*** ព្រោះសិទ្ធិនៃការធ្វើអាជីវកម្មលើផលិតផលនោះត្រូវបានបញ្ចប់នៅពេល ផលិតផលនោះត្រូវបានលក់លើកដំបូង។

# 2. ការនាំចូលស្របគ្នា (Parallel Import)

- លើកលែងតែចែងផ្សេងដោយច្បាប់ សកម្មភាពលក់បន្តជាបន្តបន្ទាប់ ជួល ឱ្យខ្ចី ឬ ទម្រង់ផ្សេងៗទៀតនៃការប្រើប្រាស់បែបពាណិជ្ជកម្ម ដោយភាគីទីបី ម្ចាស់សិទ្ធិគ្មានសិទ្ធិគ្រប់គ្រង ឬជំទាស់ឡើយ។
- បញ្ហានេះមានការពាក់ព័ន្ធនឹងការ**នាំចូលស្របគ្នា**។
- ការនាំចូលស្របគ្នានេះ រួមមានទាំងកិច្ចការពារប្រកាសនីយបត្រតក្កកម្ម ម៉ាក គំនូសឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធ។

- មានគោលការណ៍នៃការអនុវត្តចំនួន៣ ដែលទាក់ទងនឹងការនាំចូលទំនិញពាក់ម៉ាកដែលបានចុះបញ្ជី ដូចជា គោលការណ៍នៃការផុតរលត់សិទ្ធិម៉ាកជា***អន្តរជាតិ*** ជា***តំបន់ និងជាតិ(***គោលការណ៍***ដែនដី )*** នៃសិទ្ធិម្ចាស់ម៉ាក។
- ដើម្បីដឹងថាប្រទេសណាមួយ អនុម័តយកគោលការណ៍ណាមួយ ច្បាប់នៃប្រទេសនោះជាអ្នកកំណត់គោលការណ៍។
- កម្ពុជា អនុម័តយក**សិទ្ធិដែនដី** /***ជាតិ*** នៃសិទ្ធិម្ចាស់ម៉ាក(មាត្រា១១(គ))។

# 3. ការផុតរលត់សិទ្ធិជាអន្តរជាតិ នៃសិទ្ធិលើម៉ាក (International Exhaustion of Mark Rights)

- នៅពេលផលិតផលមួយ ពាក់ម៉ាកដែលបានចុះបញ្ជី បានដាក់លក់លើទីផ្សារដោយម្ចាស់ម៉ាក ឬដោយមានការយល់ព្រមពីខ្លួន សិទ្ធិផ្តាច់មុខត្រូវបានផុតរលត់ (គោលការណ៍នៃការផុតរលត់សិទ្ធិម្ចាស់ម៉ាកអន្តរជាតិ)។
- មានន័យថា ម្ចាស់ម៉ាកដែលបានចុះបញ្ជី មិនអាចជំទាស់លើការនាំចូលស្របគ្នានៃផលិតផល***សុទ្ធថ្មី*** ដែលពាក់ម៉ាករបស់ខ្លួន ក្នុងទីផ្សារបរទេសឡើយ។

# 4. គោលការណ៍ដែនដី នៃសិទ្ធិលើម៉ាក (Territorial Concept of Mark Rights)

- កម្ពុជា និង ប្រទេសមួយចំនួន ដូចជា ចក្រភពអង់គ្លេស ប្រទេសស្វីស អនុម័តយកគោលការណ៍ ដែនដីនៃសិទ្ធិម៉ាក។
- មាត្រា១១(គ) ចែងថា " សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក នឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ។
- ដូច្នេះ ម្ចាស់ម៉ាក អាចមានសិទ្ធិជំនាស់នឹងការនាំចូលស្របគ្នា។

# B-ភាពផ្តាច់មុខនៃសិទ្ធិកម្មសិទ្ធិបញ្ញា(Exclusivity)

- ជាទូទៅ ប្រព័ន្ធកម្មសិទ្ធិបញ្ញា ផ្តល់សិទ្ធិផ្តាច់មុខឱ្យម្ចាស់សិទ្ធិស្របច្បាប់នៃកម្មសិទ្ធិបញ្ញា ដូចជា ម៉ាក ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូសឧស្សាហកម្ម សិទ្ធិអ្នកនិពន្ធ សៀគ្វីបង្រួម (IC) សិទ្ធិអ្នកបង្កាត់ពូជដំណាំ ..... លើអ្វីទាំងអស់ ដែលគេបង្កើត ច្នៃប្រឌិតថ្មី។
- ប្រសិនបើ ***គ្មានសិទ្ធិផ្តាច់មុខ***ទេ ***គ្មានអ្នកណាម្នាក់ចង់បង្កើត ឬច្នៃប្រឌិតអ្វីដែលថ្មី*** ដោយសារការច្នៃប្រឌិត អាចត្រូវបានគេលួចចម្លង ឬលួចបានយ៉ាងងាយស្រួល។
- វា***មិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ***របស់យើង វិធានរបស់WTO ឬ សេដ្ឋកិច្ចទីផ្សារសេរី និងសេដ្ឋកិច្ចទីផ្សារសង្គមឡើយ។

➢ ក្នុងការអនុវត្ត ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើផលិតផលមួយ(ទំនិញ) អ្នកទទួលប្រយោជន៍សិទ្ធិផ្តាច់មុខ ជាទូទៅ ***ត្រូវចុះកិច្ចសន្យាឬកិច្ចព្រមព្រៀងសិទ្ធិផ្តាច់មុខ*** ជាមួយម្ចាស់ម៉ាកដែលបានចុះបញ្ជី ដែលរួមមាន

លក្ខខណ្ឌមួយចំនួន៖

- ❖ បរិមាណផលិតផលសរុបដែលត្រូវនាំចូលក្នុង១ឆ្នាំ( មិនត្រូវតិចជាងបរិមាណសរុបដែលធ្លាប់នាំចូល)
- ❖ តម្កល់លុយ (ជាទូទៅ មិនត្រូវតិចជាង ២០% ទៅ ៣០%)
- ❖ ១០០% ឬយ៉ាងហោចណាស់ ៣០% នៃកម្រៃសេវាផ្សព្វផ្សាយជាបន្ទុករបស់អ្នកទទួលប្រយោជន៍ និង ឬ

❖ ធានាសេវាបន្ទាប់ពីការលក់ និង ….

➢ ជាគោលការណ៍ មានការប្រកួតប្រជែងរវាងម៉ាក និងម៉ាកផ្សេងទៀត។

TOYOTA Vs NISSAN, SUZUKI, FORD, ….

➢ អ្នកប្រើប្រាស់ នឹងទទួលបានតម្លៃនិងគុណភាពសមរម្យ ដោយសារអ្នកទទួលប្រយោជន៍ ត្រូវបំពេញកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងផ្តាច់មុខដែលបានចុះហត្ថលេខា។

➢ ជាវិធីដ៏ល្អមួយ ដើម្បីការពារអ្នកប្រើប្រាស់ឱ្យទទួលបានផលិតផលសុទ្ធពិតប្រាកដ។

- ផ្អែកលើសំណើរបស់អ្នកទទួលប្រយោជន៍ និងសិទ្ធិផ្តាច់មុខជាលាយលក្ខណ៍អក្សរ ដែលផ្តល់ឱ្យដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម **អាចចេញលិខិតទទួលស្គាល់** (មិនមែនជាបញ្ជា) ឱ្យអ្នកទទួលប្រយោជន៍  និងជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចនៅតាមព្រំដែន ឱ្យចាត់វិធានការប្រឆាំងនឹងការនាំចូលខុសច្បាប់។
- ក្នុងការអនុវត្ត ក្រសួងពាណិជ្ជកម្ម មិនគាំទ្រការចេញលិខិតទទួលស្គាល់ សម្រាប់<u>**ឱសថ**</u>។

# C- សិទ្ធិឯកាធិភាព (Monopoly)

- ផ្តល់ភាពផ្តាច់មុខលើផលិតផលឬសេវា នៃសិទ្ធិរដ្ឋឬឯកជន (មិនមែនលើផលិតផលដែលពាក់ម៉ាកដែលបានចុះបញ្ជីទេ)។

*ឧទាហរណ៍:*

- ❖ ភាពផ្តាច់មុខលើការនាំចូលម៉ូតូ ( គ្មានម៉ាក គ្មានការអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី) ឬ
- ❖ ភាពផ្តាច់មុខលើការទិញ ជ័រកៅស៊ូ សណ្តែក ឬជ្រូក (គ្មានម៉ាក) ក្នុងខេត្តណាមួយ ដោយគ្មានការយល់ព្រមពីម្ចាស់ផលិតផល។

- ដូច្នេះ អាជ្ញាធររំលោភបំពានលើសិទ្ធិឯកជនរបស់ផលិតករ។
- អំពើបែបនេះ ពិតជាផ្ទុយនឹងរដ្ឋធម្មនុញ្ញរបស់យើង វិធានរបស់ WTO សេដ្ឋកិច្ចទីផ្សារសេរីនិងសេដ្ឋកិច្ចទីផ្សារសង្គម។
- ប៉ុន្តែ វាអាចជាការអនុវត្តន៍ដោយស្របច្បាប់តាមរយៈការដេញថ្លៃស្របច្បាប់ នៅពេលដែលទ្រព្យសម្បត្តិជារបស់រដ្ឋ

( រ៉ែ ផ្លូវថ្នល់ ស្ពាន អគ្គីសនី ប្រេង .......)

# D- ដំណើរការចេញលិខិតទទួលស្គាល់និងការដោះស្រាយវិវាទសិទ្ធិផ្តាច់មុខនៃការនាំចូល

1. លក្ខខណ្ឌតម្រូវ
2. ផលប្រយោជន៍មួយចំនួនពីការចេញលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខ
3. ដំណើរការចេញលិខិតទទួលស្គាល់
4. ដំណោះស្រាយវិវាទ

# 1. លក្ខខណ្ឌតម្រូវ

1. ម៉ាក *ត្រូវតែចុះបញ្ជីក្នុងប្រទេសកម្ពុជា* ដើម្បីទទួលបានសិទ្ធិផ្តាច់មុខ ដូចមានចែងក្នុងមាត្រា៣ នៃច្បាប់ម៉ាក។
2. សម្រាប់គោលបំណងប្រមូលពន្ធ អ្នកទទួលប្រយោជន៍ *ត្រូវតែជានីតិបុគ្គល។*
3. មានភស្តុតាងនៃការទទួលបាន *សិទ្ធិផ្តាច់មុខ* តាមរយៈការចេញលិខិតពី *ម្ចាស់ម៉ាកដែលបានចុះបញ្ជី* ទៅឲ្យអ្នកទទួលប្រយោជន៍ក្នុងប្រទេសកម្ពុជា ឬ ទៅអ្នកទទួលប្រយោជន៍នៅក្រៅប្រទេសកម្ពុជា បន្ទាប់មក ទៅអ្នកទទួលប្រយោជន៍នៅកម្ពុជា។ លិខិតនេះត្រូវបញ្ជាក់ថាត្រឹមត្រូវដោយសាការី ឬមេធាវី។
4. ទំនិញ *ស្មុគ្រ* និង *ថ្មី* ជាកម្មវត្ថុនៃការទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម លើកលែងតែ ឱសថ និងផលិតផលប្រើប្រាស់រួច (ជជុះ)។

# 2. ផលប្រយោជន៍មួយចំនួនពីការចេញលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខ

- មានការប្រកួតប្រជែងរវាងម៉ាក និងម៉ាកផ្សេងទៀត
  - TOYOTA Vs NISSAN, SUZUKI, FORD, ….
- អ្នកប្រើប្រាស់នឹងទទួលបានតម្លៃសមរម្យ ដោយសារអ្នកទទួលប្រយោជន៍ ត្រូវបំពេញកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងសិទ្ធិផ្តាច់មុខដែលបានចុះហត្ថលេខា
- វាជាវិធីល្អមួយដើម្បីការពារអ្នកប្រើប្រាស់ឱ្យទទួលបានផលិតផល *សុទ្ធ* និង *ថ្មី*
- បង់ពន្ធនាំចូលគ្រប់ចំនួនទាំងអស់

# 3. ដំណើរការនៃការចេញលិខិតទទួលស្គាល់

1. អ្នកទទួលប្រយោជន៍ ត្រូវផ្ញើលិខិតស្នើសុំ ទៅក្រសួងពាណិជ្ជកម្ម ដើម្បីឱ្យទទួលស្គាល់សិទ្ធិផ្តាច់មុខរបស់ខ្លួន ដែលទទួលបានពីម្ចាស់មាកដែលបានចុះបញ្ជី ដោយបង្ហាក់ម្រែផ្លូវការដែលតម្រូវ
2. ប្រសិនបើមានការខ្វះចន្លោះ អ្នកទទួលប្រយោជន៍ នឹងត្រូវបានអញ្ជើញឱ្យកែតម្រូវចំនុចខ្វះខាត
3. ក្រសួងពាណិជ្ជកម្ម នឹងចេញលិខិតទទួលស្គាល់ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ។

NB: - លិខិតទទួលស្គាល់ នឹងមានសុពលភាពរយៈពេល២ឆ្នាំ ហើយ មានប្រសិទ្ធិភាព បន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខាពីរខែ ។ លិខិតនេះ អាចបន្តជាថ្មីបាន។

- អ្នកទទួលប្រយោជន៍ ត្រូវចុះផ្សាយលិខិតទទួលស្គាល់នេះក្នុងកាសែតល្បីក្នុងរយៈពេល៣ថ្ងៃជាប់គ្នា។

# 4. ដំណោះស្រាយវិវាទ

- បច្ចុប្បន្ននេះ គ្មានបទប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទលើការនាំចូលស្របគ្នានៃទំនិញសុទ្ធថ្មីដែលរំលោភបំពានលើសិទ្ធិផ្តាច់មុខរបស់អ្នកទទួលប្រយោជន៍នៅឡើយ ( ក្រសួងពាណិជ្ជកម្ម នឹងចេញប្រកាស)។
- ផ្អែកតាមច្បាប់ម៉ាក និងការអនុវត្ត នៅពេលដែលទំនិញសុទ្ធថ្មីរំលោភបំពានលើសិទ្ធិផ្តាច់មុខនៃការនាំចូលរបស់អ្នកទទួលប្រយោជន៍ ដំណោះស្រាយដូចខាងក្រោម អាចត្រូវបានប្រើប្រាស់:

  1- រឹបអូសទំនិញនៅច្រកព្រំដែន ក្នុងពេលដឹកជញ្ជូន និង/ឬ នៅទីផ្សារ។

2- អ្នកទទួលប្រយោជន៍ និង ជនល្មើស អាចចរចាដោយៈ

a)- អនុញ្ញាតឱ្យជនល្មើសលក់ទំនិញដោយបង់សំណង សមស្របលើការខូចខាតដល់អ្នកទទួលប្រយោជន៍ ឬ

b)- ទិញទំនិញនាំចូលទាំងអស់ពីអ្នកនាំចូលតាមថ្លៃដើម ឬ

c)- ប្រសិនបើ គ្មានកិច្ចព្រមព្រៀង ទំនិញដែលនាំចូលត្រូវបញ្ជូនត្រឡប់ទៅវិញ (មិនអនុញ្ញាតឱ្យលក់ទំនិញនាំចូលក្នុងដែនដីកម្ពុជា)។

3- កំណត់ហេតុ ត្រូវចុះហត្ថលេខាដោយភាគីទាំងពីរ ដោយជនល្មើសសន្យាថាមិននាំចូលទំនិញនេះទៀតឡើយ ទោះស្ថិតក្រោមដំណោះស្រាយណាមួយក៏ដោយ។

www.CambodiaIP.gov.kh

Email: varrothsan77@gmail.com

dipr.moc@gmail.com

Tel: 012 363 843 / 088 9999 453